**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៦៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១០០៧ អនក្រ.តត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

### មាត្រា ១.-

ត្រូវបានបង្កើត "គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់" ដែលហៅកាត់ថា "គ.ប.ច." ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងយុត្តិធម៌។

គ.ប.ច. មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- | ឯកឧត្តម អង្គ វង្សវឌ្ឍនា | ប្រធាន |
| ២- | ឯកឧត្តម ហ៊ី សោភា | អនុប្រធានប្រចាំការ |
| ៣- | ឯកឧត្តម ច័ន្ទ សំណព្វ | អនុប្រធាន |
| ៤- | ឯកឧត្តម កើត រិទ្ធ | អនុប្រធាន |

៥- ឯកឧត្តម កាន ច័ន្ទមេត្តា សមាជិក
៦- ឯកឧត្តម យក់ ប៊ុនណា សមាជិក
៧- ឯកឧត្តម ប៊ុន ហុន សមាជិក
៨- ឯកឧត្តម យ៉ាង សេង សមាជិក
៩- ឯកឧត្តម សូ មុយឃៀង សមាជិក
១០-ឯកឧត្តម ថេង ច័ន្ទសង្វារ សមាជិក
១១-ឯកឧត្តម ស៊ា ម៉ៅ សមាជិក
១២-ឯកឧត្តម ប៉ែន ពេជ្រសាលី សមាជិក
១៣-ឯកឧត្តម តាន់ហ៊ាង ដាវ៉ែណ្ណ សមាជិក
១៤-ឯកឧត្តម ផូវ សំភី សមាជិក
១៥-ឯកឧត្តម ហ៊ែល ចំរើន សមាជិក
១៦-ឯកឧត្តម ស៊ូ សុជាតិ សមាជិក
១៧-ឯកឧត្តម ហ៊ីង គីមថន សមាជិក
១៨-លោក សឹង ផុស សមាជិក
១៩-លោកស្រី ចាំង ស៊ីណាត សមាជិក
២០-កញ្ញា ហេ ផល្លាសម្បត្តិ សមាជិក
២១-លោក អែម ឧត្តម សមាជិក
២២-លោក ហ៊ិន ឈុនតេង សមាជិក។

គ.ប.ច. អាចមានសមាសភាពបន្ថែមផ្សេងទៀត ដែលត្រូវជ្រើសរើសចេញពីក្នុងចំណោមឥស្សរជន ឬមន្ត្រីរាជការ ដែលមានចំណេះដឹង និងបទពិសោធន៍ការងារក្នុងវិស័យនីតិសាស្ត្រ រដ្ឋបាល សេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬអក្សរសាស្ត្រ និងត្រូវតែងតាំងដោយអនុក្រឹត្យដោយឡែក តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចាត់បញ្ជូនតំណាង ទៅតាមសេចក្តីស្នើសុំរបស់គ.ប.ច.។

**មាត្រា ២.-**

គ.ប.ច. អាចមានទីប្រឹក្សាជាតិ និងអន្តរជាតិមួយចំនួនតាមការចាំបាច់ ដែលពុំមែនជាសមាជិករបស់គណៈកម្មការនេះទេ។ ទីប្រឹក្សា ត្រូវបានអញ្ជើញឱ្យចូលរួមជាមួយគ.ប.ច. គ្រប់ពេល។ ទីប្រឹក្សាអាចជូនមតិយោបល់បាន ប៉ុន្តែពុំមានសិទ្ធិចូលរួមបោះឆ្នោតសំដែងមតិនៅក្នុងគណៈកម្មការឡើយ។

**មាត្រា ៣.-**

គ.ប.ច. មានភារកិច្ចពិនិត្យ និងអនុម័តពាក្យច្បាប់ដែលកំពុងប្រើប្រាស់ ពាក្យច្បាប់ថ្មី និងពាក្យច្បាប់ដែលបកប្រែពីភាសាបរទេស។ នីតិវិធីនៃការពិនិត្យ និងអនុម័តពាក្យច្បាប់របស់គ.ប.ច. ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងមួយ ដែលអនុម័តដោយគណៈកម្មការនេះ។

ពាក្យច្បាប់ទាំងឡាយដែលគ.ប.ច.អនុម័តរួចហើយ ត្រូវចងក្រងជាសទ្ទានុក្រម និងត្រូវបញ្ជូនទៅប្រមុខរាជរដ្ឋាភិបាល ដើម្បីសុំការប្រកាសឱ្យប្រើនៅទូទាំងប្រទេស។

គ.ប.ច. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ ដើម្បីដំណើរការការងាររបស់ខ្លួន។

**មាត្រា ៤..**

គ.ប.ច. មានលេខាធិការដ្ឋានមួយជាសេនាធិការ និងជាអង្គភាពបច្ចេកទេស ដែលជួយគណៈកម្មការក្នុងការងារព្រាងពាក្យច្បាប់ ការងាររដ្ឋបាល ការងារគេស្តុការ និងហិរញ្ញកិច្ច ព្រមទាំងការងារផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងគណៈកម្មការ។

លេខាធិការដ្ឋាននៃគ.ប.ច. មានភារកិច្ចដូចតទៅ ៖

- ព្រាងបញ្ជីពាក្យច្បាប់ និងបកប្រែពាក្យច្បាប់បរទេសមកពាក្យច្បាប់ខ្មែរ ដើម្បីពិនិត្យ និងសម្រេច ដោយរៀបចំជាសទ្ទានុក្រមពាក្យច្បាប់
- បោះពុម្ពឯកសារសម្រាប់ដំណើរការការងាររបស់គ.ប.ច.ទាំងមូល
- រៀបចំការប្រជុំរបស់គ.ប.ច.
- ធ្វើកំណត់ហេតុ និងរបាយការណ៍នៃអង្គប្រជុំ
- រៀបចំចងក្រង និងបោះពុម្ពពាក្យច្បាប់ដែលអង្គប្រជុំបានអនុម័ត
- រៀបចំបោះពុម្ពសទ្ទានុក្រមពាក្យច្បាប់ និងរដ្ឋបាល
- រៀបចំ និងចែកផ្សាយសទ្ទានុក្រមពាក្យច្បាប់ និងរដ្ឋបាល
- អនុវត្តការងារផ្សេងៗទៀតដែលគ.ប.ច.ប្រគល់ឱ្យ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគ.ប.ច. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

លេខាធិការដ្ឋាននៃគ.ប.ច. ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។ សមាសភាពនៃលេខាធិការដ្ឋាននេះ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា ៥..**

គ.ប.ច. មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិការបស់ក្រសួងយុត្តិធម៌។

គ.ប.ច. មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

**មាត្រា ៦..**

រាល់កិច្ចប្រជុំរបស់គ.ប.ច. ត្រូវទទួលបានប្រាក់បំណាច់ម៉ោងប្រជុំ។ តម្លៃប្រាក់បំណាច់ម៉ោងប្រជុំ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៧.-**

អនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣ ស្ដីពីការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយអនុក្រឹត្យនេះ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ២០១៤

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍនា**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ